ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:......៣៦......អយក.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការដឹកនាំ គ្រប់គ្រង និងរៀបចំយន្តការ កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០២៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១**.-

ត្រូវបានបង្កើតគណៈកម្មការដឹកនាំ គ្រប់គ្រង និងរៀបចំយន្តការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធាន

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០-៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ២. ឯកឧត្តម | អ៊ឹម | កុច | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. លោកជំទាវ | ទុន់ | សាអ៊ីម | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម | កុលផេង | វឌ្ឍនា | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥. ឯកឧត្តម | ពុត | សាមិត្ត | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៦. ឯកឧត្តមបណ្ឌិត | ឱម | សិទ្ធី | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧. ឯកឧត្តមបណ្ឌិត | ម៉ុក | សារ៉ុម | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត | សិត | សេង | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៩. ឯកឧត្តម | ប៊ិន | ធុំ | នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង | សមាជិក |
| ១០. លោក | ថៃ | ហេង | នាយករងវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១. លោក | វ័ន្ត | សារ៉ា | ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិកអចិន្ត្រៃយ៍ |
| ១២. លោកស្រីបណ្ឌិត | បូ | ច័ន្ទគុលិកា | ប្រធាននាយកដ្ឋានគោលនយោបាយ | សមាជិកា |
| ១៣. លោកបណ្ឌិត | សុខ | សូត្រ | ព្រឹទ្ធបុរសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៤. លោក | លី | គាង | អនុប្រធាន នា.បណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៥. លោកស្រី | នេត | អង្គារតន៍ | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកា |
| ១៦. លោក | សុង | សុខសាន្ត | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១៧. លោក | ឈួន | ប៊ុនឈឿន | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច | សមាជិក |
| ១៨. លោក | តុង | បូរិទ្ធ | អនុប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |
| ១៩. លោក | ប៊ុត | សុភាន់ | អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ២០. លោក | តាំង | សុភា | ប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ២១. លោក | ឡេង | សារី | ប្រធានការិ.នៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| ២២. លោក | អ៊ុក | សារ៉ាត់ | ប្រធានការិ.នៃនាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ និងគោលនយោបាយអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- តម្រង់ទិសរៀបចំ និងដាក់ចេញគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា
- ដឹកនាំ សម្របសម្រួល ដោះស្រាយការងារ និងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរស្ថាប័នពាក់ព័ន្ធនឹងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស ធនធានមនុស្ស និងធ្វើសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងបុព្វហេតុអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ជំរុញលើកទឹកចិត្ត និងគាំទ្រការចូលរួមលើកកម្ពស់ការអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ពិនិត្យតាមដាន វាយតម្លៃសកម្មភាពការងារ និងផ្តល់អនុសាសន៍ដល់អនុគណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋាន

- ពិនិត្យ និងសម្រេចលើផែនការយុទ្ធសាស្ត្រ ផែនការមេ និងយន្តការការងារកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ដែលបានស្នើឡើងដោយអនុគណៈកម្មការបច្ចេកទេស
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុប្រធាន និងសមាជិកទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

---

**ប្រការ ២.-**

គណៈកម្មការដឹកនាំ គ្រប់គ្រង និងរៀបចំយន្តការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវមានអនុគណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋានមួយជាជំនួយការ ដូចខាងក្រោម៖

**ក. អនុគណៈកម្មការបច្ចេកទេស** មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. ឯកឧត្តម | កុលផេង | វង្សនា | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត ឱម | | សិទ្ធី | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | អនុប្រធាន |
| ៣. លោក | រ័ត្ន | សារ៉ា | ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាន |
| ៤. លោក | ដោក | ដា | នាយករងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៥. លោក | ហ៊ត | ស៊ីនួន | នាយករងវិទ្យាស្ថានគរុកោសល្យបាត់ដំបង | សមាជិក |
| ៦. លោកបណ្ឌិត | មាឃ | ចាន់ថេង | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោក | តាំង | សុភា | ប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៨. លោក | កាក់ | រចនា | ប្រធានការិ.នៃនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៩. លោក | គឹម | សៀង | ប្រធានការិ.នៃនាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក | មឿន | ចន្ទ្រា | ប្រធានដេប៉ា.នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១១. លោកស្រី | ទូន | បញ្ញាវត្តី | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិកា |
| ១២. លោកស្រី | ឈីន | សុខគាង | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិកា |
| ១៣. លោក | អាត | សារ៉េត | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៤. លោក | យ៉ុង | សុផានា | អនុប្រធានការិ.នៃនាយកដ្ឋានអប់រំកុមារតូច | សមាជិក |
| ១៥. លោក | ឈួន | គ្រី | អនុប្រធានការិ.នៃនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ១៦. លោកស្រី | ផន | សុភា | អនុប្រធានការិ.នៃនា.បណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិកា |
| ១៧. លោក | នូ | មុនីសេដ្ឋា | អនុប្រធានការិ.នៃនា.មធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ១៨. លោក | ជ័យ | រដ្ឋា | អនុប្រធានការិ.នៃនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៩. លោកស្រី | យក់ | សុគន្ធារ៉ាវី | អនុប្រធានការិ.នៃនាយកដ្ឋានបុគ្គលិក | សមាជិកា |
| ២០. លោកស្រី | ហាក់ | វង្សនី | គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ២១. លោក | សោមនស្ស ភិរម្យ | | បុគ្គលិកអប់រំនៃនា.អភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| ២២. តំណាងដៃគូអភិវឌ្ឍន៍ | | | | សមាជិក/សមាជិកា |

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- កំណត់ក្របខណ្ឌគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើតម្រូវការក្នុងការអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា
- លើកសំណើ និងផ្ដល់យោបល់ជូនគណៈកម្មការដឹកនាំ គ្រប់គ្រង និងរៀបចំយន្តការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា លើការកែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សំដៅពង្រឹងប្រសិទ្ធភាពការផ្ដល់សេវាមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា
- ដឹកនាំការពិភាក្សា និងការពិគ្រោះយោបល់ជាមួយអន្តនាយកដ្ឋាន និងគ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកំណត់គោលការណ៍ ក្របខណ្ឌការងារ និងយន្តការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា
- ផ្ដួចផ្ដើម និងកំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ ចងក្រងឯកសារ កម្មវិធីសិក្សា កសាងនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រ និងធានានូវនិរន្តរភាពកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ
- រៀបចំ អភិវឌ្ឍ និងកែលម្អគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ និងយន្តការការងារកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា
- ជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ និងយន្តការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ដើម្បីធានាប្រក្រតីភាព និងប្រសិទ្ធភាពនៃដំណើរការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សានៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំយន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្ដល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ
- លើកសំណើពាក់ព័ន្ធផ្សេងៗជូនគណៈកម្មការគ្រប់គ្រង ដឹកនាំ និងរៀបចំយន្តការការងារមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់គណៈកម្មការដឹកនាំ គ្រប់គ្រង និងរៀបចំយន្តការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា
- អនុប្រធាន សមាជិក សមាជិកាទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**២**. ត្រូវបានចាត់តាំងការិយាល័យតម្រង់ទិសវិជ្ជាជីវៈ នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ជា **លេខាធិការដ្ឋាន** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. លោក | តាំង | សុភា | ប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | ប្រធាន |
| ២. លោកស្រី | ទូន | បញ្ញាវត្តី | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាន |
| ៣. លោក | អាត | សារ៉េត | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាន |
| ៤. លោកស្រី | ឈីន | សុខគាង | អនុប្រធានការិ.នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាន |
| ៥. លោកស្រី | អ៊ួង | សុចិន្ដា | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិកា |
| ៦. លោក | ភឹម | បូផាន់ | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. កញ្ញា | ហៀម | អានកន្និដ្ឋា | បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិកា |

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម៖

- បំពេញភារកិច្ចរដ្ឋបាល និងចាត់ចែងរៀបចំកិច្ចប្រជុំរបស់គណៈកម្មការ និងអនុគណៈកម្មការបច្ចេកទេស
- សម្របសម្រួល ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់គណៈកម្មការ និងអនុគណៈកម្មការ
- បំពេញភារកិច្ចផ្សេងៗទៀតដែលគណៈកម្មការ និងអនុគណៈកម្មការប្រគល់ជូន។

**ប្រការ ៣.-**

សេចក្ដីសម្រេចលេខ៤១ អយក.សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រង ដឹកនាំ និងរៀបចំយន្តការការងារប្រឹក្សាអាជីព ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានយុវជន នាយក វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ វិទ្យាស្ថានគរុកោសល្យបាត់ដំបង ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីជនដូចប្រការ១ ប្រការ២ ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១២រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២២

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានអប់រំ
-អគ្គនាយកដ្ឋានឧត្តមសិក្សា
-អគ្គនាយកដ្ឋានយុវជន
-វិទ្យាស្ថានជាតិអប់រំ
-វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
-វិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-គ្រប់នាយកដ្ឋានពាក់ព័ន្ធ
«ដើម្បីជូនជ្រាបជាព័ត៌មាន»
-សាមីជន «ដើម្បីអនុវត្ត»
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ